

# ប្រព័ន្ធប្រកាសឱ្យដឹងមុនក្នុងទីក្រុង

## អ្វីជាប្រព័ន្ធប្រកាសឱ្យដឹងមុនក្នុងទីក្រុង?

ប្រព័ន្ធប្រកាសឱ្យដឹងមុនក្នុងទីក្រុងត្រូវបានបង្កើតឡើងដោយអង្គការភីន (People In Need) ដែលបានទទួលជំនួយពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុនៅកម្ពុជា ដំណាក់កាលទី៣ ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងរដ្ឋបាលក្រុងបាត់ដំបង គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត(គ.គ.ម.ខ) និង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(គ.ជ.គ.ម.)។ប្រព័ន្ធប្រកាសឱ្យដឹងមុនក្នុងទីក្រុងនេះគឺជាបណ្តាញផ្តល់ព័ត៌មានថ្មីមួយដើម្បីផ្សព្វផ្សាយសារប្រកាសអាសន្នទៅកាន់ប្រជាពលរដ្ឋក្នុងក្រុងបាត់ដំបងអំពីគ្រោះទឹកជំនន់និងរាល់មុខសញ្ញាគ្រោះថ្នាក់ដទៃទៀត។

រៀងរាល់ពេលដែលគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្តទទួលបានព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់ធម្មជាតិផ្សេងៗពីក្រសួងធនធានទឹកនិងឧតុនិយមមន្ទីរធនធានទឹកនិងឧតុនិយមខេត្តបាត់ដំបង និងឧបករណ៍ទេពមច្ឆាដែលវាស់កម្ពស់ទឹកដោយស្វ័យប្រវត្តិដែលជាប្រភពព័ត៌មានត្រឹមត្រូវ និង ទុកចិត្តបាន នោះ មន្ត្រី គ.គ.ម.ខ. ដែលទទួលបន្ទុកក្នុងការផ្ញើរសារជូនដំណឹង និងរៀបចំខ្លឹមសារព័ត៌មានប្រកាសឱ្យដឹងមុន នឹងធ្វើការផ្សព្វផ្សាយនូវសារប្រកាសអាសន្ន តាមរយៈប្រព័ន្ធប្រកាសឱ្យដឹងមុន ដែលមាន មេក្រូប្រកាសអាសន្នស្វ័យប្រវត្តិទៅកាន់ប្រជាពលរដ្ឋងាយរងគ្រោះក្នុងក្រុងបាត់ដំបង។

## តើប្រព័ន្ធប្រកាសឱ្យដឹងមុនក្នុងទីក្រុងដំណើរការយ៉ាងដូចម្តេច?

ប្រព័ន្ធប្រកាសឱ្យដឹងមុនក្នុងទីក្រុង ដែលមានមេក្រូជាឧបករណ៍ ប្រកាសអាសន្នស្វ័យប្រវត្តិ គឺជាបណ្តាញផ្តល់ព័ត៌មានថ្មីមួយក្នុងក្រុងបាត់ដំបង។ មេក្រូត្រូវបានបង្កើតឡើងដើម្បីផ្សព្វផ្សាយសារប្រកាសអាសន្នទាក់ទងនឹងគ្រោះមហន្តរាយធម្មជាតិជាពិសេសទឹកជំនន់ទៅកាន់ប្រជាពលរដ្ឋដែលងាយរងគ្រោះ។ ក្រោមគម្រោងនេះ មុខងារដែលមានស្រាប់ ក្នុងប្រព័ន្ធគ្រប់គ្រងការរៀបចំនិងផ្ញើរសារ ១២៩៤ ដែលមន្ត្រីទទួលបន្ទុក គ.ជ.គ.ខ.កំពុងប្រើប្រាស់ ត្រូវបានវិវត្តន៍ខ្លួនដោយភ្ជាប់ជាមួយនឹងបណ្តាញថ្មី ដែលជាមេក្រូ ប្រកាសអាសន្នស្វ័យប្រវត្តិ។

មន្ត្រី គ.ជ.គ.ខ. ចេញសារប្រកាសអាសន្នទៅកាន់ប្រជាពលរដ្ឋអំពីគ្រោះថ្នាក់ធម្មជាតិ ជាពិសេសគ្រោះទឹកជំនន់ តាមរយៈមេក្រូ បន្ទាប់ពីសារប្រកាសអាសន្នត្រូវបានរៀបចំរួចរាល់សម្រាប់ចេញផ្សាយ តាមរយៈ ប្រព័ន្ធគ្រប់គ្រងការរៀបចំនិងផ្ញើរសារ ១២៩៤ ។មេក្រូប្រកាសអាសន្ន បានបង្កើតឡើងជាមួយនឹងប្រព័ន្ធគ្រប់គ្រងស្វ័យប្រវត្តិដែលអាចទទួលព័ត៌មានដែលបានផ្ញើរចេញពីគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្តដែលបញ្ជាតាមរយៈប្រព័ន្ធគ្រប់គ្រងការរៀបចំនិងផ្ញើរសារ ១២៩៤ ។បន្ទាប់ពីការទទួលបានសារ ប្រព័ន្ធគ្រប់គ្រងស្វ័យប្រវត្តិរបស់មេក្រូបញ្ជូនសំលេងសារទៅកាន់ប្រព័ន្ធបន្លើសំលេងអេឡិចត្រូនិច របស់មេក្រូ នោះប្រជាជនរស់នៅក្នុងតំបន់គោលដៅនឹងលឺ សារប្រកាសចេញពីមេក្រូដោយស្វ័យប្រវត្តិ។ បច្ចុប្បន្នសារប្រកាសឱ្យដឹងមុនអាច ផ្សាយសារទៅកាន់ប្រជាជនក្នុង សហគមន៍ក្នុងចម្ងាយ ប្រមាណ ៥០ ម៉ែត្រការ៉េនៃទីតាំងដែលបានតម្លើង ។ថាមពលព្រះអាទិត្យ ឬសូឡាជាប្រភពថាមពលរបស់ មេក្រូប្រកាសអាសន្ន។

ប្រជាពលរដ្ឋរស់នៅតំបន់ងាយរងគ្រោះក្នុងក្រុងបាត់ដំបងនឹងទទួលបានសារប្រកាសឱ្យដឹងពីគ.ជ.គ.ខ.ផ្សាយតាមរយៈមេក្រូប្រកាសឱ្យដឹងដែលតម្លើងទីតាំងគោលដៅក្នុងខេត្តបាត់ដំបង ។ ប្រព័ន្ធប្រកាសឱ្យដឹងមុនក្នុងទីក្រុង ដែលមានមេក្រូជាបណ្តាញប្រកាសឱ្យដឹងមុន គឺជាយន្តការផ្សព្វផ្សាយដ៏ល្អមួយក្នុងអំឡុងពេលមានគ្រោះអាសន្នដែលទាក់ទងនឹងទឹកជំនន់និងគ្រោះថ្នាក់ធម្មជាតិផ្សេងៗ។សារប្រកាសអាសន្នដែលចែករំលែករវាងអាជ្ញាធរមូលដ្ឋានជាមួយនឹងប្រជាពលរដ្ឋមានលក្ខណៈស្តង់ដាររួមនេះនឹងក្លាយជាបណ្តាញផ្សព្វផ្សាយមានប្រសិទ្ធភាព និង ទាន់ពេលវេលាសម្រាប់ការរៀបចំចាត់វិធានការសមស្របក្នុងការការពារខ្លួនក្នុងសហគមន៍។

**សម្រាប់ព័ត៌មានបន្ថែមអំពីគម្រោង៖** ០៨៩ ៨៥០ ៤៧៤

www.peopleinneed.net

EWS 1294 - Early Warning System

គាំទ្រថវិកាដោយ៖
CAMBODIA CLIMATE CHANGE ALLIANCE
Implemented by: Funded by:
ស៊ុយអែត Sverige

គាំទ្រដោយ៖ អនុវត្តដោយ៖

ប្រព័ន្ធផ្តល់មតិ

០៩២ ៩៣៩ ១៦៩/ ០៩៨ ៩៣៩ ១៦៩/ ០៧១ ៣៩ ៣៩ ១៦៩

យើងរីករាយនឹងទទួលយកគ្រប់យោបល់ ការសាកសួរ ឬបណ្តឹងផ្សេងៗពាក់ព័ន្ធនឹងកម្មវិធី




ប្រពន្ធ័ប្រកាសឱ្យដឹងមុនក្នុងទីក្រុង ធ្វើឱ្យសហគមន៍លោកអ្នកៈ

- កាត់បន្ថយនូវអត្រាក្នុងការបាត់បង់អាយុជីវិត ផ្ទះសម្បែង ទ្រព្យសម្បត្តិ និងរបស់របរផ្សេងៗទៀតពីគ្រោះទឹកជំនន់
- ជួយឱ្យសហគមន៍របស់អ្នកទទួលបានព័ត៌មានសម្រាប់ត្រៀមបង្ការមុនពេលទឹកជំនន់មកដល់។


គាំទ្រថវិកាដោយៈ
CAMBODIA CLIMATE CHANGE ALLIANCE
Implemented by:
Funded by:
ស៊ុយអែត
Sverige
គាំទ្រដោយៈ
អនុវត្តដោយៈ


ប្រព័ន្ធផ្តល់មតិ

០៩២ ៩៣៩ ១៦៩/ ០៩៨ ៩៣៩ ១៦៩/ ០៧១ ៣៩ ៣៩ ១៦៩

យើងរីករាយនឹងទទួលយកគ្រប់យោបល់ ការសាកសួរ ឬបណ្តឹងផ្សេងៗពាក់ព័ន្ធនឹងកម្មវិធី